AUSTRALIAN EMBASSY
PHNOM PENH

# សេចក្តីប្រកាសព័ត៌មាន

## គំនិតផ្តួចផ្តើមរបស់អូស្ត្រាលីក្នុងការបង្កើនសមត្ថភាពលើផ្នែកអង្គការពាណិជ្ជកម្មពិភពលោកដល់ប្រទេសក្នុងតំបន់

ការរីកចំរើនឆ្ពោះទៅរកការជួយដល់បណ្តាប្រទេសនៅអាស៊ីអគ្នេយ៍ ដើម្បីបានចូលរួមនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក និងឈានមួយជំហានទៅមុខទៀតនៅទីក្រុងភ្នំពេញ ជាមួយនឹងសិក្ខាសាលាមានរយៈពេលពីរថ្ងៃ គឺថ្ងៃទី ៨-៩ ខែធ្នូ ឆ្នាំ២០០៣ ដើម្បីរៀបចំគំរោងកម្មវិធីដែលត្រូវផ្តល់ជំនួយថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងលើកកំពស់សមត្ថភាពរបស់បណ្តាប្រទេសនៅក្នុងតំបន់ ដើម្បីឱ្យមានលក្ខណៈសម្បត្តិសមស្របក្នុងការចូលរួមជាមួយអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

បណ្តាប្រទេសដែលចូលរួមនៅក្នុងកម្មវិធីបង្កើនសមត្ថភាពក្នុងតំបន់លើផ្នែក WTO រួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម ។ ប្រទេសថៃ គឺជាសមាជិកស្ថាបនិកមួយរបស់អង្គការ WTO ហើយកម្ពុជា ត្រូវបានយល់ព្រមឱ្យចូលជាសមាជិកមួយនៃអង្គការនេះ នៅកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៅ កាន់គុន នាពេលថ្មីៗនេះ ។ ដោយឡែកវៀតណាម និង ឡាវ កំពុងស្ថិតនៅក្នុងដំណើរការឆ្ពោះទៅរកការយល់ព្រម ។

សិក្ខាសាលានេះនឹងផ្តោតទៅលើការបង្កើនការយល់ដឹងឱ្យកាន់តែច្បាស់នូវជំរើសគោលនយោបាយពាណិជ្ជកម្មនៅក្នុងក្របខ័ណ្ឌរបស់ WTO និង បង្កើនសមត្ថភាពក្នុងតំបន់ក្នុងការធ្វើការសិក្សាស្រាវជ្រាវ និង ធ្វើការវិភាគប្រកបដោយគុណភាពទៅលើផលប៉ះពាល់របស់កិច្ចព្រមព្រៀង WTO ។

សិក្ខាសាលានេះរៀបចំឡើងបន្ទាប់ពីការពិគ្រោះយោបល់ដ៏ទូលំទូលាយ ហើយនឹងមានការចូលរួមពីសិក្ខាកាមដែលជាតំណាងក្រសួង ស្ថាប័នស្រាវជ្រាវ និង សហគមន៍ពាណិជ្ជកម្ម ។

បន្ទាប់ពីកិច្ចប្រជុំWTOថ្នាក់រដ្ឋមន្ត្រីនៅដូហា រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសការផ្តល់ជំនួយថវិកាប្រហែល ២,២ លានដុល្លារអាមេរិក សំរាប់កម្មវិធីបង្កើនសមត្ថភាពក្នុងតំបន់លើផ្នែកWTO ។ សិក្ខាសាលានេះ ធ្វើឱ្យមានការរីកចំរើនក្នុងការរៀបចំឆ្ពោះទៅរកការសំរេចដោយជោគជ័យនៃកិច្ចប្រឹងប្រែងនេះ ។

*ព័ត៌មានបន្ថែមសូមទាក់ទង:*
លោកស្រី ផ្លឺរ ដេវីស Fleur Davies លេខាទីមួយ (សហប្រតិបត្តិការអភិវឌ្ឍន៍)
ស្ថានទូតអូស្ត្រាលី
ទូរស័ព្ទ: ២១៣ ៤៧០ លេខបន្ត ៣០៨